# ព្រះរាជក្រឹត្យ

នស/រកត/០៦០៦/២៣៤

## ស្តីពី

## ការកែសម្រួលព្រះរាជក្រឹត្យ

## លេខ នស/រកត/០៩៩៥/៦៥ ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ១៩៩៥

## ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៥/៦៥ ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

**មាត្រាមួយ :** ត្រូវបានកែសម្រួលមាត្រា ២, មាត្រា ៣, មាត្រា ៤, មាត្រា ៦, មាត្រា ៨, មាត្រា ៩ និង មាត្រា ១៣ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៥/៦៥ ចុះថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ហៅកាត់ "អ.ជ.ប.គ.ញ" ដែលមានស្វ័យភាពរដ្ឋបាល និងហិរញ្ញវត្ថុ មានខ្លឹមសារដូចតទៅ :

**មាត្រា ២ ថ្មី :**

អាជ្ញាធរជាតិ មានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| - រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ប្រធាន |
| - ឥស្សរជនមួយរូប មានឋានៈស្មើរដ្ឋមន្ត្រី | អនុប្រធានអចិន្ត្រៃយ៍ |
| - រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ | អនុប្រធាន |
| - រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| - រដ្ឋមន្ត្រីក្រសួងការពារជាតិ | សមាជិក |
| - រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| - រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| - រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| - រដ្ឋមន្ត្រីក្រសួងសុខាភិបាល | សមាជិក |
| - រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| - រដ្ឋមន្ត្រីក្រសួង ពត៌មាន | សមាជិក |
| - រដ្ឋមន្ត្រីក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| - ទេសាភិបាលធនាគារជាតិនៃកម្ពុជា | សមាជិក |
| - អគ្គលេខាធិការនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន | សមាជិកនិងជាលេខាធិការ |

រដ្ឋមន្ត្រី រដ្ឋលេខាធិការ និងបុគ្គលផ្សេងទៀត ដែលពាក់ព័ន្ធនឹងរបៀបវារៈ អាចត្រូវបានអញ្ជើញចូលរួមប្រជុំ ។

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ប្រជុំយ៉ាងតិច ២ ដង ក្នុងមួយឆ្នាំ ។ កាលបើប្រធានអវត្តមាន អាជ្ញាធរជាតិ ត្រូវប្រជុំក្រោមអធិបតីភាពនៃអនុប្រធាន ។

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានសិទ្ធិធ្វើត្រាប្រើប្រាស់របស់ខ្លួន។

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ ។

**មាត្រា ៣ ថ្មី :**

អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន កំណត់ន័យ និងលើកទិសដៅក្នុងវិស័យដូចខាងក្រោម :

- ការសម្របសម្រួល និងការអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

- ការអនុវត្តនីបទប្បញ្ញត្តិអនុសញ្ញាទោល ស្តីពីគ្រឿងញៀន ឆ្នាំ១៩៦១ ដែលបានធ្វើវិសោធនកម្ម ដោយពិធីសារឆ្នាំ១៩៧២, អនុសញ្ញាស្តីពីសារធាតុដែលធ្វើឱ្យប៉ះពាល់ប្រព័ន្ធសរសៃប្រសាទ ឆ្នាំ ១៩៧១ និងអនុសញ្ញារបស់អង្គការសហប្រជាជាតិប្រឆាំងនឹងការចរាចរខុសច្បាប់នូវគ្រឿង ញៀន និងសារធាតុដែលធ្វើឱ្យប៉ះពាល់សរសៃប្រសាទ ឆ្នាំ១៩៨៨ ។
- ការរៀបចំតាក់តែងអត្ថបទច្បាប់ និងបទប្បញ្ញត្តិទាំងឡាយ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដោយសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ។
- ការអប់រំ និងបង្ការកុំឱ្យមានការប្រើបំពានគ្រឿងញៀន ។
- ការលើកទឹកចិត្តដល់គ្រប់អ្នកផ្តួចផ្តើមគំនិតក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។
- ការប្រយុទ្ធប្រឆាំងនឹងជំនួញគ្រឿងញៀនខុសច្បាប់ សារធាតុសម្រាប់ផ្សំថ្នាំញៀន ហើយនិងការ សំអាតប្រាក់បានមកពីជំនួញគ្រឿងញៀនខុសច្បាប់ ។
- ការបង្កើតមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ។ ការរៀបចំ និង ការប្រព្រឹត្តទៅនៃមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ត្រូវកំណត់ ដោយអនុក្រឹត្យ ។
- ការបណ្តុះបណ្តាលបុគ្គលិកសម្រាប់ការប្រយុទ្ធប្រឆាំងនឹងជំនួញគ្រឿងញៀនខុសច្បាប់ ការបង្វែរ សារធាតុផ្សំសម្រាប់ផលិតគ្រឿងញៀន ការសំអាតប្រាក់បានមកពីជំនួញគ្រឿងញៀនខុសច្បាប់ និងការប្រើប្រាស់គ្រឿងញៀន ។
- ការសិក្សាស្រាវជ្រាវពីការញៀនជាតិពុល ។
- ការសហប្រតិបត្តិការអន្តរជាតិ ក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

អាជ្ញាធរជាតិត្រូវធានាធ្វើឱ្យ ព្រះរាជាណាចក្រកម្ពុជា បានបំពេញកាតព្វកិច្ច ដូចមានចែងក្នុង អនុសញ្ញាអន្តរជាតិទាំងក្នុងផ្ទៃប្រទេស ទាំងក្នុងទំនាក់ទំនងជាមួយប្រទេសឯទៀត ឬ អង្គការអន្តរជាតិ ដែលទទួលបន្ទុកត្រួតពិនិត្យគ្រឿងញៀន ព្រមទាំងការដាក់ឱ្យដំណើរការនូវយន្តការជាតិ និងអន្តរជាតិ សម្រាប់ការត្រួតពិនិត្យគ្រឿងញៀន។

**មាត្រា ៤ ថ្មី :**

អាជ្ញាធរជាតិមានថវិកាស្វយ័ត ដើម្បីដំណើរការការងាររបស់ខ្លួន ។

ធនធាន និងថវិកានេះ បានមកពី :

- ថវិកាជាតិ ដែលស្ថិតក្នុងគំរោងថវិការួមរបស់ក្រសួងមហាផ្ទៃ ។

- ប្រាក់ជំនួយ អំណោយ ឬវិភាគទានដែលផ្តល់ជូនអាជ្ញាធរជាតិ ដោយរដ្ឋាភិបាលបរទេស អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល សម្រាប់ការប្រយុទ្ធប្រឆាំងគ្រឿងញៀន ។
- ទ្រព្យ និងរបស់មានតំលៃដែលបានមកពីការអនុវត្តន៍សេចក្តីសម្រេចរឹបអូសរបស់តុលាការ ពីជំនួញគ្រឿងញៀនខុសច្បាប់ ហើយបញ្ចូលទៅក្នុងបេឡាមូលនិធិជាតិ សម្រាប់ប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

អាជ្ញាធរជាតិនេះ នឹងត្រួតពិនិត្យការប្រើប្រាស់មូលនិធិខាងលើរបស់អគ្គលេខាធិការ សម្រាប់ប្រយុទ្ធប្រឆាំងគ្រឿងញៀន ។ អាជ្ញាធរជាតិ មានសិទ្ធិចាត់ចែងថវិកា និងទ្រព្យសម្បត្តិដែលបញ្ចូលទៅក្នុងបេឡា មូលនិធិជាតិខាងលើ ។

**មាត្រា ៦ ថ្មី :**

អគ្គលេខាធិការដ្ឋាន ត្រូវដឹកនាំដោយអគ្គលេខាធិការមួយរូប និងមានអគ្គលេខាធិការរង ជាជំនួយការ ។

អគ្គលេខាធិការ អគ្គលេខាធិការរង ត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យ ។ ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានភារកិច្ចដាក់ជូននាយករដ្ឋមន្ត្រីនូវសមាសភាពខាងលើ ដើម្បីស្នើសុំព្រះរាជក្រឹត្យតែងតាំង ។

អគ្គលេខាធិការដ្ឋាន ត្រូវស្ថិតនៅក្នុងរចនាសម្ព័ន្ធនៃក្រសួងមហាផ្ទៃ និងស្ថិតនៅក្រោមការដឹកនាំគ្រប់គ្រងរបស់ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ។

**មាត្រា ៨ ថ្មី :**

អគ្គលេខាធិការ មានសិទ្ធិស្នើសុំមន្ត្រីរាជការពីក្រសួង-ស្ថាប័នពាក់ព័ន្ធ មកបំរើការងារនៅក្នុងអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន តាមរយៈប្រធានអាជ្ញាធរជាតិ ។ មន្ត្រីរាជការ ដែលបំរើការងារនៅក្នុងអគ្គលេខាធិការដ្ឋាន ត្រូវផ្ទេរក្របខ័ណ្ឌទៅក្នុងក្របខ័ណ្ឌមន្ត្រីរាជការរបស់ក្រសួងមហាផ្ទៃ ។

អគ្គលេខាធិការ មានសិទ្ធិស្នើសុំជ្រើសរើសក្របខ័ណ្ឌថ្មីពីគំរោងក្របខ័ណ្ឌមន្ត្រីរាជការ របស់ក្រសួងមហាផ្ទៃ តាមរយៈប្រធានអាជ្ញាធរជាតិ ។

**មាត្រា ៩ ថ្មី :**

អគ្គលេខាធិការ គ្រប់គ្រងថវិកាស្វយ័ត និងបែងចែកមូលនិធិដែលបានផ្តល់ឱ្យ សម្រាប់ប្រយុទ្ធប្រឆាំងគ្រឿងញៀន ដើម្បីប្រើប្រាស់ទៅតាមតំរូវការជាក់លាក់របស់គ្រឹះស្ថានសាធារណៈ ឬ អ្នកចូលរួមជាឯកជន ក្រោមការត្រួតពិនិត្យ ការចង្អុលទិស ការសម្រេចរបស់អាជ្ញាធរជាតិ ។

**មាត្រា ១៣ ថ្មី :**

សម្ដេចនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រដ្ឋមន្ត្រីក្រសួងពត៌មាន រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ទេសាភិបាលធនាគារជាតិ និងអគ្គលេខាធិការ នៃ អ.ជ.ប.គ.ញ ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

**មាត្រាពីរ :** បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រាបី :** ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០៦*

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

*ពរ/ល.០៦០៦.២៨៩* **នរោត្តម សីហមុនី**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ : ៥៦៣ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**